និយ័តករបរធនបាលកិច្ច
Trust Regulator

គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector in the Kingdom of Cambodia

លេខ ២២ ចេញផ្សាយថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១
No. 22 Released on November 29, 2021

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# វិធានសម្រាប់មន្ត្រីអធិការកិច្ចបរធនបាលកិច្ចក្នុងការប្រតិបត្តិការអនុវត្តច្បាប់
# Rules for Trust Inspectors in Carrying Out Law Enforcement

- ស្លៀកពាក់ឯកសណ្ឋាន
- ពាក់សញ្ញាសម្គាល់
- ពាក់សញ្ញាសក្តិ
- មានលិខិតបញ្ជាបេសកកម្ម

នៅពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចបរធនបាលកិច្ចត្រូវស្លៀកពាក់ឯកសណ្ឋាន, ពាក់សញ្ញាសម្គាល់, និងសញ្ញាសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម។ ឯកសណ្ឋាន, សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ចត្រូវកំណត់ដោយអនុក្រឹត្យ។

បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ចត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) តាមសំណើរបស់និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**)។ មន្ត្រីអធិការកិច្ចបរធនបាលកិច្ចដែលបំពេញមុខងារ និងភារកិច្ចត្រឹមត្រូវតាមច្បាប់ស្តីពីបរធនបាលកិច្ច ត្រូវបានការពារដោយច្បាប់ (*ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩; ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១; អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១*)។

While carrying out law enforcement, trust inspectors shall wear uniforms and insignias, and bring along with them the letter of dispatch for mission. The uniform, insignias and signal-rank of the trust inspectors shall be determined by a sub-decree.

Formalities and procedure for trust inspection shall be determined by a Prakas of the Minister of Economy and Finance and Chairman of the Council of the Non-Bank Financial Services Authority (**NBFSA**) at the request of the **TR**. Trust inspectors who perform their duties and responsibilities in good faith shall be protected by law (*Law on Trust, 2019; Law on the Organization and Functioning of the NBFSA, 2021; Sub-Decree on the Organization and Functioning of Units Under the NBFSA, 2021*).

**អត្ថបទ៖ ណង សេរីវុធ | Article: Sereyvuth Nong**

**ឯកសារយោង | References**:

- មាត្រា៤០,៤១&៤២, ច្បាប់ស្តីពីបរធនបាលកិច្ច. (២០១៩).
- ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ. (២០២១).
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ. (២០២១).

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.